# ទំនាយប្រចាំខែទាំង ១២

+មនុស្សប្រុស-ស្រីណាសដែលកើតខែ ១ គឺខែមិគសិរ ទំនាយទាយថាជាមនុស្សធុនមធ្យម មានចិត្តស្រឡាញ់រាប់អានអ្នកដទៃដោយស្មោះត្រង់ បើប្រុសមិនទាន់មានវាសនាល្អ ដោយសារស្រីជួយយិតយោង ។

+មនុស្សប្រុស-ស្រីណាដែលកើតខែ ២ គឺខែបុស្ស ទំនាយទាយថាជាមនុស្សនឿយព្រួយច្រើន ទ្រព្យសម្បត្តិរកបានដោយក្រលំបាក ជួយយកអាសារគេ ច្រើនបានទុក្ខទោសដល់ខ្លួន ។

+មនុស្សប្រុស-ស្រីណាដែលកើតខែ ៣ គឺខែមាឃ ទំនាយទាយថា អ្នកនោះជាមនុស្សមានចិត្ត ក្លាហាន ជួយយកអាសារនាយចៅហ្វាយបានល្អប្រសើរ ជាមនុស្សមានប្រាជ្ញាវាងវៃ ឆ្លៀវឆ្លាស់ក្នុងការប្រកបការងារ ។

+មនុស្សប្រុស-ស្រិណាដែលកើតខែ ៤ គឺខែផល្គុន ទំនាយទាយថាជាមនុស្សមានបុណ្យវាសនាល្អ បើសេពគប់មនុស្សសំបូរដាំដែងនឹងបានល្អប្រសើរ អ្នកនោះមានគូរស្រករសំដីច្រើនរឹងរុះបន្តិច ។

+មនុស្សប្រុស-ស្រីណាដែលកើតខែ ៥ គឺខែចែត្រ ទំនាយទាយថាអ្នកនោះនឹងបានជាធំ ដោយមានគេជួយផ្គងផ្តើម ជាមនុស្សមានបញ្ញាជាន់ខ្ពស់ ច្រើនមានចិត្តស្មោះត្រង់នឹងអ្នកដទៃ មានញាតិមិត្តស្រឡាញ់រាប់អានច្រើន ។

+មនុស្សប្រុស-ស្រីណាដែលកើតខែ ៦ គឺខែពិសាខ ទំនាយទាយថា ជាមនុស្សចិត្តស្រាល ឆាប់ ខឹង ពាក្យពោលច្រើនមិនពិរោះពិសារ តែអ្នកនោះមានសំណាង ដោយបានគូរស្រករជាអ្នកមានបុណ្យវាសនាល្អ ។

+មនុស្សប្រុស-ស្រីណាដែលកើតខែ ៧ គឺខែជេស្ឋ ទំនាយទាយថា ជាមនុស្សធុនកណ្តាល អាចរកស៊ីចិញ្ចឹមជីវិតបានផលល្អបង្គួរ អ្នកនោះនឹងបានជួបគូរស្រករដែលមានពាក្យពេជន៍សំដីពិរោះពិសារ គួរជាទីចូលចិត្តរាប់អានពីអ្នកផងទាំងពួង ។

+មនុស្សប្រុស-ស្រីណាដែលកើតខែ ៨ គឺខែអាសាធ ទំនាយទាយថា ជាមនុស្សដែលមានទុក្ខព្រួយជារឿយៗ អ្នកនោះនឹងបានជួបគូរស្រករដែលមានចិត្តកាចឬស្យា មិនជាទីរាប់អានឡើយ ។

+មនុស្សប្រុស-ស្រីណាដែលកើតខែ ៩ គឺខែស្រាពណ៍ ទំនាយទាយថាជាមនុស្សមានចិត្តទំរន់ក្នុង ខ្លួនមិនសូវឈ្លាសវៃ តែមានចិត្តស្មោះត្រង់ ។

+មនុស្សប្រុស-ស្រីណាដែលកើតខែ ១០ គឺខែភទ្របទ ទំនាយទាយថាជាមនុស្សមានសន្តានចិត្ត ក្លៀវក្លាប្រាជ្ញាឈ្លាសវៃ ជួយយកអាសារចៅហ្វាយនាយបានល្អ និងមានគូរស្រករជាមនុស្សមានត្រកូល ខ្ពង់ខ្ពស់ តែទឹកចិត្តមិនសូវស្របគ្នា ។

+មនុស្សប្រុស-ស្រីណាដែលកើតខែ ១១ គឺខែអស្សុជ ទំនាយទាយថា ជាមនុស្សមានបុណ្យ វាសនាល្អ តែច្រើនមានសត្រូវជាមួយនឹងភេទផ្ទុយពីខ្លួន អ្នកនោះនឹងមានគូរគ្រងជាមនុស្សកាចបន្តិច តែចិត្តគំនិតល្អប្រសើរ ។

+មនុស្សប្រុស-ស្រីណាដែលកើតខែ ១២ គឺខែកក្តិក ទំនាយទាយថាជាមនុស្សមានអត្តចរិតថ្លៃថ្នូរគួរជាទីរាប់អានផៃញាតិផងទាំងពួង និងមានគូរគ្រងជាអ្នកដែលមានវោហាសីបាន ។